ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ :.....០៧៦៧......ន.ទ.ក.

# សេចក្តីសម្រេច
# ស្តីពី
# ការគ្រប់គ្រងលេខកូដទូរគមនាគមន៍

## និយ័តករទូរគមនាគមន៍កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៩/៤៤១ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំង និងផ្តល់ឋានៈជាប្រធាន និងសមាជិកនៃនិយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៨/១៩១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការតែងតាំង និងផ្តល់ឋានៈជាសមាជិកនៃនិយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការកំណត់កម្រៃនៃការប្រើប្រាស់លេខទូរស័ព្ទ និងលេខទូរគមនាគមន៍
- បានឃើញប្រកាសរួមលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញប្រកាសរួមលេខ ៤៩៩ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយនិយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញប្រកាសលេខ ៣១៣ បទ.ប្រក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការប្រគល់ភារកិច្ច និងសិទ្ធិក្នុងការផ្តល់សេវាសាធារណៈមួយចំនួនរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជូន និយ័តករទូរគមនាគមន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់និយ័តករទូរគមនាគមន៍កម្ពុជា។



វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh

## សម្រេច

## ផ្នែកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងគ្រប់គ្រងលេខកូដទូរគមនាគមន៍ ប្រកបដោយប្រសិទ្ធភាព និងស្របតាមប្លង់លេខទូរគមនាគមន៍ជាតិនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-** គោលដៅ

សេចក្តីសម្រេចនេះមានគោលដៅកំណត់អំពីទម្រង់ ការផ្តល់ ការប្រើប្រាស់ ការកែប្រែ ការផ្ទេរ ការដកហូត និងការប្រគល់លេខកូដទូរគមនាគមន៍។

**ប្រការ ៣.-** វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះប្រតិបត្តិករទូរគមនាគមន៍ និងអ្នកទទួលលិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរគមនាគមន៍គ្រប់ប្រភេទ លើកលែងលេខទូរស័ព្ទចល័ត និងលេខទូរស័ព្ទអចល័ត ដែលកំណត់ដោយបទប្បញ្ញត្តិ ឬសេចក្តីណែនាំដោយឡែក។

**ប្រការ ៤.-** និយមន័យនៃពាក្យបច្ចេកទេស

និយមន័យនៃពាក្យបច្ចេកទេសក្នុងសេចក្តីសម្រេចនេះ ត្រូវបានកំណត់ដូចតទៅ៖

- **លេខកូដទូរគមនាគមន៍** សំដៅដល់បណ្តាលេខកូដខ្លី និងលេខកូដសម្គាល់សេវាពិសេស ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ១ នៃសេចក្តីសម្រេចនេះ ដែលត្រូវផ្តល់ជូនបណ្តាក្រសួង ស្ថាប័នរដ្ឋ/ឯកជន អង្គការ ប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនសម្រាប់ផ្តល់សេវាទូរគមនាគមន៍ ។
- **លេខកូដសម្រាប់សេវាគ្រាអាសន្ន** សំដៅដល់លេខកូដទូរគមនាគមន៍ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ១ នៃសេចក្តីសម្រេចនេះ ដែលត្រូវបានប្រើប្រាស់ក្នុងគ្រាអាសន្ន ដោយសាធារណជន និងបានផ្តល់ទៅដល់អង្គភាពនគរបាលជាតិ អង្គភាពពន្លត់អគ្គិភ័យ និងអង្គភាពសេវារថយន្តសង្គ្រោះបន្ទាន់ដោយឥតគិតថ្លៃ។
- **ប្លង់លេខទូរគមនាគមន៍ជាតិ** សំដៅដល់ប្លង់ដែលត្រូវបានរៀបចំដើម្បីគ្រប់គ្រង និងកំណត់អំពីលេខ លេខកូដ និងសញ្ញាសម្គាល់ពិសេសទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **ការកែប្រែលេខកូដទូរគមនាគមន៍** សំដៅដល់ការបន្ថែម ឬបន្ថយចំនួនខ្ទង់លេខ ឬការផ្លាស់ប្តូរទម្រង់លេខ ឬប្រភេទសេវានៃលេខកូដទូរគមនាគមន៍ ដោយ និយ័តករទូរគមនាគមន៍កម្ពុជា (**ន.ទ.ក.**) ស្របតាមប្លង់លេខទូរគមនាគមន៍ជាតិ ឬបទប្បញ្ញត្តិជាធរមាន។
- **អ្នកទទួលលិខិតអនុញ្ញាត** សំដៅដល់នីតិបុគ្គលដែលបានទទួលលិខិតអនុញ្ញាតពី **ន.ទ.ក.** ដើម្បីប្រើប្រាស់លេខកូដទូរគមនាគមន៍។

## ផ្នែកទី ២

## ការគ្រប់គ្រងលេខកូដទូរគមនាគមន៍

**ប្រការ ៥.-** ការផ្តល់លេខកូដទូរគមនាគមន៍

**ន.ទ.ក.** ជាស្ថាប័នមានសមត្ថកិច្ចក្នុងការទទួល ពិនិត្យ និងសម្រេចលើសំណើសុំលិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរគមនាគមន៍គ្រប់ប្រភេទ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចនេះ និងលេខកូដទូរគមនាគមន៍ផ្សេងទៀតស្របតាមប្លង់លេខទូរគមនាគមន៍ជាតិ។

រាល់ការចំណាយលើការស្ថាបនា និងតភ្ជាប់បណ្ដាញរវាងប្រព័ន្ធរបស់អ្នកទទួលលិខិតអនុញ្ញាត ទូរគមនាគមន៍កម្ពុជា និងប្រតិបត្តិករទូរគមនាគមន៍ ដើម្បីដាក់ឱ្យដំណើរការលេខកូដ ដែលផ្ដល់ដោយ **ន.ទ.ក.** គឺជាបន្ទុករបស់អ្នកទទួលលិខិតអនុញ្ញាត។ ដោយឡែក ថ្លៃសេវានៃការសន្ទនាពីគ្រប់បណ្ដាញទូរស័ព្ទទាំងអស់ ត្រូវកំណត់ដោយកិច្ចព្រមព្រៀងរវាងអ្នកទទួលលិខិតអនុញ្ញាត និង ប្រតិបត្តិករទូរគមនាគមន៍ដែលផ្ដល់ការតភ្ជាប់ និងត្រូវស្របតាមលក្ខខណ្ឌនៃស្តង់ដាបច្ចេកទេស គុណភាពនៃសេវា គោលការណ៍តម្លាភាព និងថ្លៃសមរម្យ។ ថ្លៃសេវានៃការសន្ទនាពីគ្រប់បណ្ដាញទូរស័ព្ទទាំងអស់ ត្រូវបានលើកលែងចំពោះការហៅទៅកាន់លេខកូដទូរគមនាគមន៍សម្រាប់ផ្ដល់សេវាគ្រាអាសន្ន ស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៦**.- លក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំ

នីតិវិធី ទម្រង់ បែបបទ និងលក្ខខណ្ឌ សម្រាប់ការស្នើសុំ និងផ្ដល់លិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរគមនាគមន៍ត្រូវកំណត់ដោយសេចក្ដីណែនាំរបស់ **ន.ទ.ក.** ។

**ប្រការ ៧**.- ការប្រើប្រាស់លេខកូដទូរគមនាគមន៍

អ្នកទទួលលិខិតអនុញ្ញាតត្រូវប្រើប្រាស់លេខកូដទូរគមនាគមន៍ដែល **ន.ទ.ក.** បានផ្ដល់ជូនឱ្យអស់លទ្ធភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

**ប្រការ ៨**.- កាតព្វកិច្ចប្រើប្រាស់លេខកូដទូរគមនាគមន៍

អ្នកទទួលលិខិតអនុញ្ញាត ត្រូវប្រើប្រាស់លេខកូដទូរគមនាគមន៍ឲ្យបានត្រឹមត្រូវ ស្របតាមប្រភេទ និងទម្រង់លេខកូដទូរគមនាគមន៍នីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃសេចក្ដីសម្រេចនេះ ។

អ្នកទទួលលិខិតអនុញ្ញាតមិនត្រូវបង្កើតលេខកូដទូរគមនាគមន៍ខុសពីលេខកូដទូរគមនាគមន៍ដែល **ន.ទ.ក.** បានផ្ដល់ជូន និងការកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ។

**ប្រការ ៩**.- ការកែប្រែលេខកូដទូរគមនាគមន៍

**ន.ទ.ក.** មានសិទ្ធិកែប្រែលេខកូដទូរគមនាគមន៍ដែលបានផ្ដល់ជូនក្រសួង ស្ថាប័នរដ្ឋ/ឯកជន អង្គការ សមាគម ប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុននានា ស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១០**.- ការផ្ទេរលេខកូដទូរគមនាគមន៍

រាល់ការផ្ទេរការប្រើប្រាស់លេខកូដទូរគមនាគមន៍ ត្រូវស្នើសុំការអនុញ្ញាតពី **ន.ទ.ក.** ។

ការផ្ទេរលេខកូដទូរគមនាគមន៍ពុំមានសុពលភាពឡើយ បើពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពី **ន.ទ.ក.** ។

**ប្រការ ១១**.- ការប្រគល់លេខកូដទូរគមនាគមន៍

អ្នកទទួលលិខិតអនុញ្ញាតអាចស្នើសុំប្រគល់លេខកូដទូរគមនាគមន៍គ្រប់ប្រភេទជូន **ន.ទ.ក.**។ ចំពោះប្រតិបត្តិករទូរស័ព្ទចល័ត អចល័ត មាត់ច្រកទូរគមនាគមន៍អន្តរជាតិ និងសេវាសំឡេងតាមអាយភី (VoIP) ត្រូវមាន ឬរក្សាទុកលេខកូដខ្លីប្រតិបត្តិករយ៉ាងតិចចំនួន ០២ (ពីរ) ដែលត្រូវប្រើប្រាស់សម្រាប់សេវាសាកសួរព័ត៌មានទូទៅ និងបញ្ហារអាក់រអួលសេវា ស្របតាមប្លង់លេខទូរគមនាគមន៍ជាតិ ។

ការស្នើសុំប្រគល់លេខកូដទូរគមនាគមន៍ជូន **ន.ទ.ក.** វិញអាចធ្វើបានគ្រប់ពេលនៃឆ្នាំនីមួយៗ (ឆ្នាំ n )។ ចំពោះកម្រៃនៃការប្រើប្រាស់លេខប្រចាំឆ្នាំសម្រាប់ឆ្នាំ n មិនត្រូវបានបង្វិលជូនវិញឡើយ។

អ្នកទទួលលិខិតអនុញ្ញាតពុំតម្រូវឱ្យបង់កម្រៃនៃការប្រើប្រាស់លេខកូដទូរគមនាគមន៍សម្រាប់ឆ្នាំបន្ទាប់ (ឆ្នាំ n+1)ឡើយ ក្នុងករណីការប្រគល់លេខនេះធ្វើបានមុនដំណាច់ឆ្នាំ n ។

អ្នកទទួលលិខិតអនុញ្ញាតត្រូវទូទាត់បំណុលនៃការប្រើប្រាស់លេខនោះ ជូន **ន.ទ.ក.** ស្របតាមបទប្បញ្ញត្តិជាធរមាន និងទទួលខុសត្រូវរាល់បាតុភាពទាំងឡាយដែលកើតឡើងជាយថាហេតុ ក្រោយពេលការប្រគល់លេខកូដទូរគមនាគមន៍នោះ ។

**ប្រការ ១២.**- ការដកហូតលេខកូដទូរគមនាគមន៍

**ន.ទ.ក.** មានសិទ្ធិដកហូតលេខកូដទូរគមនាគមន៍ដែលបានផ្តល់ជូនក្រសួង ស្ថាប័នរដ្ឋ/ឯកជន អង្គការ សមាគម ប្រតិបត្តិករទូរគមនាគមន៍ និងអ្នកទទួលលិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរគមនាគមន៍គ្រប់ប្រភេទ ករណីមានការតម្រូវដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន ឬក្នុងករណីដូចខាងក្រោម៖

- អ្នកទទួលលិខិតអនុញ្ញាតពុំបានប្រើប្រាស់លេខកូដទូរគមនាគមន៍នោះក្នុងរយៈពេល ០១ (មួយ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទទទួលបានលិខិតអនុញ្ញាតពី **ន.ទ.ក.**។
- អ្នកទទួលលិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរគមនាគមន៍នោះ មិនស្របតាមប្រការ ៨ នៃសេចក្តីសម្រេចនេះ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតដែលនៅជាធរមាន។
- ការប្រើប្រាស់លេខកូដទូរគមនាគមន៍នោះ ធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍ ឬអ្នកប្រើប្រាស់ផ្សេងទៀត ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ
- អ្នកទទួលលិខិតអនុញ្ញាតពុំបានបង់កម្រៃនៃការប្រើប្រាស់លេខកូដទូរគមនាគមន៍នោះស្របតាម បទប្បញ្ញត្តិជាធរមាន។

**ប្រការ ១៣.**- ការដកហូតអាជ្ញាបណ្ណពាក់ព័ន្ធ

**ន.ទ.ក.** មានសិទ្ធិដកហូតរាល់អាជ្ញាបណ្ណ ដែលពាក់ព័ន្ធនឹងករណីការផ្ទេរ ការប្រគល់ និង ការដកហូតលេខកូដទូរគមនាគមន៍ ដូចមានចែងក្នុងប្រការ ១០ ប្រការ ១១ និង ប្រការ ១២ នៃសេចក្តីសម្រេចនេះ ធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការ ឬមិនអាចដំណើរការអាជីវកម្មផ្តល់សេវាទូរគមនាគមន៍ នៃអាជ្ញាបណ្ណនោះ ។

**ប្រការ ១៤.**- ទោសប្បញ្ញត្តិ

ករណីអនុវត្តផ្ទុយពីសេចក្តីសម្រេចនេះ អ្នកទទួលលិខិតអនុញ្ញាត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិផ្សេងទៀតដែលនៅជាធរមាន។

## ផ្នែកទី ៣
## អន្តរប្បញ្ញត្តិ

**ប្រការ ១៥.**- អន្តរប្បញ្ញត្តិ

អ្នកទទួលបានលិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរគមនាគមន៍ ដែលផ្តល់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ **ន.ទ.ក.** កន្លងមក ត្រូវដាក់លេខកូដទាំងនោះឱ្យដំណើរការ និងប្រើប្រាស់ឱ្យបានត្រឹមត្រូវស្របតាមប្រភេទ និងទម្រង់លេខកូដទូរគមនាគមន៍នីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និង ឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចនេះ ។

ចំពោះអ្នកទទួលបានលិខិតអនុញ្ញាត ដែលបានបង្កើតលេខកូដខុសពីលេខកូដទូរគមនាគមន៍ដែលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ **ន.ទ.ក.** បានផ្តល់ជូន អាចបន្តប្រើលេខកូដនោះក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីសេចក្តីសម្រេចនេះចូលជាធរមាន។ ផុតរយៈពេលនេះ អ្នកទទួលបានលិខិតអនុញ្ញាត ត្រូវប្រើប្រាស់លេខកូដទូរគមនាគមន៍ដែលផ្តល់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ **ន.ទ.ក.** ស្របតាមប្រភេទ និងទម្រង់លេខកូដទូរគមនាគមន៍នីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និង ឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចនេះ។

ចំពោះប្រតិបត្តិករទូរស័ព្ទចល័ត អចល័ត មាត់ច្រកទូរគមនាគមន៍អន្តរជាតិ និងសេវាសំឡេងតាមអាយភី (VoIP) ដែលពុំទាន់មានលេខកូដដើម្បីប្រើសម្រាប់សេវាសាកសួរព័ត៌មានទូទៅ និងបញ្ហារអាក់រអួលសេវា ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតពី **ន.ទ.ក.** ស្របតាមលក្ខខណ្ឌ និងនីតិវិធីជាធរមាន ។

**ប្រការ ១៦**.- អវសានប្បញ្ញត្តិ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៧**.- ការអនុវត្ត

សមាជិក **ន.ទ.ក.** ប្រធាននាយកដ្ឋាន ប្រធានអង្គភាពក្រោមឱវាទ **ន.ទ.ក.** ប្រតិបត្តិករទូរគមនាគមន៍ និងអ្នកទទួលលិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរគមនាគមន៍ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ BR.

ថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០២០

**ប្រធាន**

**ម៉ុង ចរិយា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១ ៖ ប្រភេទលេខកូដទូរគមនាគមន៍

## ភ្ជាប់នឹងសេចក្តីសម្រេចលេខ.០៧៦ ស.ល.ក.ចុះថ្ងៃទី.១៦....ខែ.មេសា.....ឆ្នាំ២០២០

## ស្តីពីការគ្រប់គ្រងលេខកូដទូរគមនាគមន៍

| លេខកូដទូរគមនាគមន៍ | | | |
|---|---|---|---|
| ល.រ | ប្រភេទលេខកូដ | កំណត់សម្គាល់ | ប្រភេទសេវា |
| 1. | 00X | - ០០លេខនាំមុខសម្រាប់ហៅទូរស័ព្ទទៅអន្តរជាតិ<br>- X សម្គាល់លេខប្រតិបត្តិករ<br>- X = 1,2,...,9 | លេខកូដសម្គាល់មាត់ច្រកទូរគមនា-គមន៍អន្តរជាតិ IDD (International Direct Dialing) Gateway Access Code) |
| 2. | 10X | - X សម្គាល់លេខសេវា<br>- X = 0,1,2,...,9 | លេខកូដសាកល្បងអន្តរជាតិ<br>( បម្រុងទុក ) |
| 3. | 11X | - X សម្គាល់ប្រភេទសេវា<br>- X = 0,1,2,....,9 | លេខកូដខ្លីសម្រាប់សេវាគ្រាអាសន្ន |
| 4. | 12YX | - Y = 0,1,2,3,4<br>- X = 0,1,2,....,9<br>- X និង Y សម្គាល់ប្រភេទសេវា | លេខកូដបម្រុងសេវាមាត់ច្រកអន្តរជាតិ |
| | | - Y = 5,6,7,8,9<br>- X = 0,1,2,...,9<br>- X និង Y សម្គាល់ក្រសួង/ស្ថាប័ន/អង្គការ/ក្រុមហ៊ុន | លេខកូដខ្លីសម្រាប់អតិថិជន ( ក្រសួង/ស្ថាប័ន/អង្គការ/ក្រុមហ៊ុន ) |
| 5. | 13X | - X សម្គាល់លេខប្រតិបត្តិករ<br>- X = 0,1,2,...,9 | លេខកូដសម្គាល់សេវាផេកជីង ( Paging) ប្រើប្រាស់តាមតំបន់ក្នុងប្រទេស |
| 6. | 14XY, 15XY | - X និង Y= 0,1,2,...,9<br>- X សម្គាល់លេខប្រតិបត្តិករ<br>- Y សម្គាល់លេខបម្រើសេវាដែល Y អាចកំណត់ការប្រើប្រាស់ដោយប្រតិបត្តិករ លើកលែងតែ៖<br>• Y = 1 ប្រើសម្រាប់សេវាសាកសួរព័ត៌មានទូទៅ<br>• Y = 2 ប្រើសម្រាប់បញ្ហាអាក់រអួលសេវា | លេខកូដខ្លីសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ |
| 7. | 15X, 16X, 17X | - X សម្គាល់លេខប្រតិបត្តិករ<br>- X = 0,1,2,...,9 | លេខកូដសម្គាល់មាត់ច្រកទូរគមនា-គមន៍អន្តរជាតិ (VoIP Gateway Access Code) |
| 8. | 1800-ABXXXX | - AB សម្គាល់លេខប្រតិបត្តិករ<br>- A = 1,2,3....,9 ( លើកលែង 0 និង 8 )<br>- B = 0,1,2....,9<br>- X = 0,1,2....,9 | លេខកូដថ្លៃហ្វ្រី (Toll-Free) |

| | | | |
|---|---|---|---|
| 9. | 1800-8XX | - X សម្គាល់លេខសេវា<br>- X = 0,1,2,...,9 | លេខកូដសម្រាប់សេវា Home Country Direct ( បម្រុងទុក ) |
| 10. | 1900- ABXXXX | - AB សម្គាល់លេខប្រតិបត្តិករ<br>- A = 1,2,3....,9 ( លើកលែង 0 )<br>- B = 0,1,2....,9<br>- X = 0,1,2....,9 | លេខកូដព្រីមៀមរ៉េត (Premium Rate) |
| 11. | 456XX | - X សម្គាល់លេខប្រតិបត្តិករ<br>- X = 0,1,2,...,9 | លេខកូដបណ្ដាញចល័ត Mobile Network Code (MNC) សម្រាប់សម្គាល់ប្រតិបត្តិករទូរស័ព្ទចល័ត |
| 12. | 89855XX | - X សម្គាល់លេខប្រតិបត្តិករ<br>- X = 0,1,2,...,9 | លេខអត្តសញ្ញាណប្រតិបត្តិករប្រើប្រាស់សម្គាល់កាតបង់ប្រាក់ Issuer Identification Number (IIN) |
| 13. | 950XX | - X សម្គាល់លេខប្រតិបត្តិករ<br>- X = 0,1,2...,9 | លេខកូដសម្គាល់សេវាផេកជីង ( Paging) ប្រើប្រាស់ក្នុងប្រទេស |
| | +855950XX | - X សម្គាល់លេខប្រតិបត្តិករ<br>- X = 0,1,2...,9<br>- (+855) លេខកូដប្រទេសកម្ពុជា | លេខកូដសម្គាល់សេវាផេកជីង ( Paging) ប្រើប្រាស់ជាអន្តរជាតិ |
| 14. | A-B-B | - A = 0,1,2,...,63 (6 bits)<br>- B = 0,1,2,...,15 (4 bits) | លេខកូដចំណុចស៊ីញ៉ាល់ជាតិ (NSPC – National Signaling Point Code) |
| 15. | X-Y-X | - X = 0,1,2,...,7 (3 bits)<br>- Y = 0,1,2,...,255 (8 bits) | លេខកូដចំណុចស៊ីញ៉ាល់អន្តរជាតិ (ISPC – International Signaling Point Code) |

**ឧបសម្ព័ន្ធទី២ ៖ ទម្រង់ និងការប្រើប្រាស់លេខកូដទូរគមនាគមន៍**

**ភ្ជាប់នឹងសេចក្តីសម្រេចលេខ០៧៦ សអត ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០២០**

**ស្តីពីការគ្រប់គ្រងលេខកូដទូរគមនាគមន៍**

## ១. លេខកូដសម្គាល់មាត់ច្រកទូរគមនាគមន៍អន្តរជាតិ ( IDD Gateway Access Code ) ( 00X )

លេខកូដសម្គាល់មាត់ច្រកទូរគមនាគមន៍អន្តរជាតិ International Direct Dialing (IDD) ប្រើសម្រាប់ផ្តល់សេវាហៅទូរស័ព្ទចេញទៅក្រៅប្រទេសដោយផ្ទាល់ដែលមានទម្រង់ដូចខាងក្រោម៖




## ២. លេខកូដសម្រាប់សាកល្បងអន្តរជាតិ ( 10X )

លេខកូដសាកល្បងអន្តរជាតិ ប្រើសម្រាប់ការសាកល្បងសេវា Transmission, 1 KHz Tone និង Loop back ពីប្រតិបត្តិករអន្តរជាតិមួយទៅប្រតិបត្តិករអន្តរជាតិមួយទៀត។

| លេខកូដ | ប្រភេទសេវា |
|---|---|
| 10X | លេខកូដសាកល្បងអន្តរជាតិ<br>- X = 0,1,2,….,9 |

## ៣. លេខកូដខ្លីសម្រាប់សេវាគ្រាអាសន្ន (11X)

លេខកូដខ្លីសម្រាប់សេវាគ្រាអាសន្ន គឺជាលេខកូដខ្លី ៣ ខ្ទង់សម្រាប់ផ្តល់ជូនអង្គភាពនគរបាលជាតិ អង្គភាពពន្លត់អគ្គិភ័យ និងអង្គភាពសេវារថយន្តសង្គ្រោះបន្ទាន់ ដែលប្រើប្រាស់ក្នុងគ្រាអាសន្នដោយសាធារណជន។

| លេខកូដ | ប្រភេទសេវា |
|---|---|
| 11X | លេខកូដខ្លីសម្រាប់សេវាគ្រាអាសន្ន<br>- X = 0,1,2,….,9 |

## ៤. លេខកូដខ្លីសម្រាប់អតិថិជន (12YX)

លេខកូដសម្រាប់អតិថិជន គឺជាលេខកូដខ្លី ៤ ខ្ទង់សម្រាប់ផ្តល់ជូន ក្រសួង ស្ថាប័នរដ្ឋ/ឯកជន អង្គការ សមាគម ប្រតិបត្តិករ ទូរគមនាគមន៍ និងក្រុមហ៊ុននានា ដើម្បីផ្តល់សេវាជូនអតិថិជន។

| លេខកូដ | ប្រភេទសេវា |
|---|---|
| 12YX | លេខកូដខ្លីសម្រាប់អតិថិជន(ក្រសួង/ស្ថាប័ន/អង្គការ/ក្រុមហ៊ុន)<br>- Y = 5,6,7,8,9<br>- X = 0,1,2,…,9 |

សម្គាល់៖ ចំពោះ Y = 0,1,2,3,4 ត្រូវកំណត់ជាលេខកូដបម្រុងសម្រាប់សេវាដែលត្រូវផ្តល់ដោយមាត់ច្រកអន្តរជាតិ ។

## ៥. លេខកូដសម្រាប់សេវាផេកជីង ( Paging) (13X, 950XX, +855950XX)

លេខកូដសម្រាប់ផ្តល់សេវាផេកជីង (Paging) ត្រូវកំណត់ដូចខាងក្រោម៖

- លេខ 13X សេវាផេកជីង Paging ប្រើប្រាស់តាមតំបន់ក្នុងប្រទេស
- លេខ 950XX សេវាផេកជីង Paging ប្រើប្រាស់ក្នុងប្រទេស
- លេខ +855950XX សេវាផេកជីង Paging ប្រើប្រាស់ជាអន្តរជាតិ ។

## ៦. លេខកូដខ្លីសម្រាប់ប្រតិបត្តិករ (14XY, 15XY)

លេខកូដខ្លីសម្រាប់ប្រតិបត្តិករ គឺជាលេខកូដខ្លី ៤ ខ្ទង់ ដែលត្រូវផ្តល់ជូនប្រតិបត្តិករយកទៅប្រើប្រាស់សម្រាប់បម្រើសេវាកម្មផ្សេងៗ ដូចជាការសាកសួរព័ត៌មានទូទៅ ការអោក់អួលសេវា និងសេវាបន្ថែមផ្សេងៗទៀត។

| លេខកូដ | ប្រភេទសេវា |
|---|---|
| 14XY, 15XY | - X និង Y= 0;1;2;…;9<br>- X សម្គាល់លេខប្រតិបត្តិករ<br>- Y សម្គាល់លេខបម្រើសេវាដែល Y អាចកំណត់ការប្រើប្រាស់ដោយប្រតិបត្តិករ លើកលែងតែ៖<br>• Y = 1 ប្រើសម្រាប់សេវាសាកសួរព័ត៌មានទូទៅ<br>• Y = 2 ប្រើសម្រាប់បញ្ហាអោក់អួលសេវា |

## ៧. លេខកូដសម្រាប់សម្គាល់មាត់ច្រកទូរគមនាគមន៍អន្តរជាតិ (VoIP Gateway Access Code) (15X, 16X, 17X)

លេខកូដសម្រាប់សេវាសម្លេងតាមអាយភី (VoIP) ត្រូវផ្តល់ជូនប្រតិបត្តិករប្រើសម្រាប់ផ្តល់សេវាសំឡេងតាមអាយភី (VoIP ) ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការហៅចេញ និងទទួលការហៅចូលជាសំឡេងតាមរយៈសេវាពីកុំព្យូទ័រទៅកុំព្យូទ័រ កុំព្យូទ័រទៅទូរស័ព្ទ ទូរស័ព្ទទៅកុំព្យូទ័រ ឬទូរស័ព្ទទៅទូរស័ព្ទ ដែលមានទីតាំងនៅក្នុងប្រទេស ឬ ក្រៅប្រទេសកម្ពុជា ។

| លេខកូដ | ប្រភេទសេវា |
| --- | --- |
| 15X, 16X, 17X | - X សម្គាល់លេខប្រតិបត្តិករ<br>- X = 0,1,2;...,9 |

### ៨. លេខកូដសម្រាប់សេវាថូលហ្វ្រី (Toll-Free)

លេខកូដសេវាថូលហ្វ្រី (1800) សំដៅក្បាលលេខទូរស័ព្ទសម្រាប់ផ្តល់សេវាអាជីវកម្ម ដែលអ្នកប្រើប្រាស់អាចហៅទូរស័ព្ទចូលដោយមិនគិតថ្លៃនៅក្នុងប្រទេស។ ប្រតិបត្តិករផ្តល់សេវាថូលហ្វ្រីត្រូវទទួលបន្ទុកលើការបង់កម្រៃនៃការហៅទូរស័ព្ទដែលបានទទួល។ លេខសម្រាប់ផ្តល់សេវា Toll-Free ត្រូវមានចំនួន ១០ (ដប់) ខ្ទង់ និងមានទម្រង់ដូចខាងក្រោម៖

**ទម្រង់លេខកូដសម្រាប់ផ្តល់សេវា ថូលហ្វ្រី (Toll-Free)**




សម្គាល់៖

- A = 1;2;3....;9 (លើកលែង 0 និង 8)
- B = 0;1;2....;9
- X = 0;1;2....;9

### ៩. លេខកូដសម្រាប់សេវា Home Country Direct

លេខកូដសម្រាប់សេវា Home Country Direct ត្រូវបានប្រើសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់ហៅទូរស័ព្ទចូលមកលេខទូរស័ព្ទនៅក្នុងប្រទេសវិញដោយផ្ទាល់នៅពេលធ្វើដំណើរនៅក្រៅប្រទេស តាមរយៈការចុចលេខកូដ 1800 881 XXX---X ។ ទម្រង់នៃលេខកូដសម្រាប់សេវា Home Country Direct ដូចខាងក្រោម៖

**ទម្រង់លេខកូដសម្រាប់សេវា Home Country Direct**



## ១០. លេខកូដសម្រាប់សេវាព្រីមៀមរ៉េត (Premium Rate)

លេខកូដព្រីមៀមរ៉េត (1900) សំដៅក្បាលលេខទូរស័ព្ទសម្រាប់ផ្តល់សេវាអាជីវកម្ម ដែលអ្នកប្រើប្រាស់អាចហៅទូរស័ព្ទចូល និងត្រូវបង់កម្រៃដែលបានកំណត់មួយនៅក្នុងប្រទេស ។ សេវាព្រីមៀមរ៉េត រួមមានដូចជាសេវាសាកសួរព័ត៌មានពីអ្នកផ្តល់សេវា និងសេវាកំសាន្តនានា ។ លេខសម្រាប់ផ្តល់សេវាព្រីមៀមរ៉េត 1900 ត្រូវមានចំនួន ១០ ( ដប់ ) ខ្ទង់ និងមានទម្រង់ដូចខាងក្រោម៖

**ទម្រង់លេខកូដសម្រាប់ផ្តល់សេវា ព្រីមៀមរ៉េត (Premium Rate)**




សម្គាល់៖

- AB សម្គាល់លេខប្រតិបត្តិករ
- A = 1;2;3....;9 ( លើកលែង 0 )
- B = 0;1;2....;9
- X = 0;1;2....;9

## ១១. លេខកូដសម្រាប់សេវាបណ្តាញចល័ត Mobile Network Codes (MNC)

លេខកូដបណ្តាញចល័ត (MNC) សំដៅលេខកូដដែលត្រូវបូករួមបញ្ចូលគ្នាជាមួយលេខកូដទូរស័ព្ទចល័តនៃប្រទេស (MCC – Mobile Country Code) សម្រាប់សម្គាល់បណ្តាញទូរស័ព្ទចល័តនៅក្នុងប្រទេសនីមួយៗជាអន្តរជាតិ ។ ស្របតាមអនុសាសន៍ ITU-T E.212. បានកំណត់ដូចខាងក្រោម៖

- លេខកូដទូរស័ព្ទចល័តប្រទេស (MCC) ផ្តល់ដោយ ITU ជូនប្រទេសកម្ពុជាគឺលេខ 456

- លេខកូដបណ្តាញចល័ត (MNC) មានលេខ ២ ខ្ទង់ក្នុងទម្រង់លេខពី "00" ទៅ "99" ដែលត្រូវកំណត់ និងផ្តល់ដោយ ន.ទ.ក. ជូន ប្រតិបត្តិករទូរស័ព្ទចល័ត ។

- លេខអត្តសញ្ញាណអ្នកប្រើប្រាស់ទូរស័ព្ទចល័ត (MSIN) ប្រើសម្រាប់សម្គាល់អ្នកប្រើប្រាស់ទូរស័ព្ទចល័ត មានចំនួនលេខអតិបរមា 10 ខ្ទង់ និងត្រូវផ្តល់ដោយប្រតិបត្តិករ ។

| IMSI | | |
|---|---|---|
| **MCC** | **MNC** | **MSIN** |
| 3 digits | 2 digits | Maximum 10 digits |
| 456 | 00-99 | XXXXXXXXXX |
| ចំនួនលេខអតិបរមា 15 Digits | | |

- IMSI (International Mobile Subscription Identity): អត្តសញ្ញាណអន្តរជាតិនៃអ្នកប្រើប្រាស់ទូរស័ព្ទចល័ត
- MCC (Mobile Country Code): លេខកូដទូរស័ព្ទចល័តនៃប្រទេស
- MNC (Mobile Network Code): លេខកូដបណ្តាញចល័ត
- MSIN (Mobile Subscription Identification Number): លេខអត្តសញ្ញាណអ្នកប្រើប្រាស់ទូរស័ព្ទចល័ត ( ក្នុងប្រទេស )

## ១២. លេខអត្តសញ្ញាណប្រតិបត្តិករប្រើប្រាស់សម្គាល់កាតបង់ប្រាក់ ( IIN - Issuer Identification Number)

លេខអត្តសញ្ញាណប្រតិបត្តិករប្រើប្រាស់សម្គាល់កាតបង់ប្រាក់ ត្រូវកំណត់បែងចែកតាមវិស័យ ប្រទេស និងប្រតិបត្តិករស្របតាមអនុសាសន៍ ITU-T E.164 [2] ដែលមានទម្រង់ដូចខាងក្រោម៖




## ១៣. សូចនាករបណ្តាញ (NI - Network Indicator)

សូចនាករបណ្តាញ Network Indicator (NI) គឺជាលេខស៊ីញ៉ាល់ដែលត្រូវបានប្រើនៅក្នុងបណ្តាញទំនាក់ទំនងប្រព័ន្ធស៊ីញ៉ាល់លេខ៧ ( Signaling System No.7)។ សូចនាករបណ្តាញ (NI) កំណត់ប្រភេទនៃសារ (Message) ក្នុងពេលបញ្ជូនស៊ីញ៉ាល់លេខ៧ ដែលត្រូវបែងចែករវាងការបញ្ជូនសារស៊ីញ៉ាល់ជាតិ និងការបញ្ជូនសារស៊ីញ៉ាល់អន្តរជាតិ។ នៅប្រទេសកម្ពុជា ការផ្តល់ និងការប្រើប្រាស់សូចនាករបណ្តាញ (NI) មានទម្រង់ ២ ប៊ីត ប៉ៃណារី កូដ (2-bits binary code) ដែលកំណត់ចាប់ពីលេខ ០ ដល់ ៣ ដូចខាងក្រោម៖

- NI = 00 = 0 សំដៅលើបណ្តាញស៊ីញ៉ាល់អន្តរជាតិកំពុងប្រើប្រាស់
- NI = 01 = 1 សំដៅលើបណ្តាញស៊ីញ៉ាល់អន្តរជាតិសម្រាប់បម្រុងទុក
- NI = 10 = 2 សំដៅលើបណ្តាញស៊ីញ៉ាល់ជាតិកំពុងប្រើប្រាស់
- NI = 11 = 3 សំដៅលើបណ្តាញស៊ីញ៉ាល់ជាតិសម្រាប់បម្រុងទុក

## ១៤. លេខកូដចំណុចស៊ីញ៉ាល់ជាតិ (NSPC - National Signalling Point Codes)

លេខកូដចំណុចស៊ីញ៉ាល់ជាតិសំដៅលេខសម្គាល់ប្រើប្រាស់នៅក្នុងបណ្តាញស៊ីញ៉ាល់លេខ ៧ (Signaling System No.7) សម្រាប់ការតភ្ជាប់បណ្តាញរវាងបមាណីស៊ីញ៉ាល់លេខ ៧ នៅក្នុងប្រទេស។

ការបែងចែកលេខកូដចំណុចស៊ីញ៉ាល់ជាតិត្រូវកំណត់ស្របតាមអនុសាសន៍ ITU-T Q. 708 ដែលមានចំនួន ១៤ ប៊ីត ប៉ៃណារី កូដ (14-bits binary code) និងមានទម្រង់ដូចខាងក្រោម៖

| ទម្រង់/ខ្នង់ | National Signalling Point Codes (NSPC) | | |
|---|---|---|---|
| | A | B | B |
| លេខប៊ីត (Bit) | 6 bits 000000-111111 | 4 bits 0000-1111 | 4 bits 0000-1111 |
| លេខនព្វន្ត (Decimal) | លេខពី 0 ដល់ 63 | លេខពី 0 ដល់ 15 | លេខពី 0 ដល់ 15 |

**១៥. លេខកូដចំណុចស៊ីញ៉ាល់អន្តរជាតិ (ISPC - International Signalling Point Codes)**

លេខកូដចំណុចស៊ីញ៉ាល់អន្តរជាតិសំដៅលេខសម្គាល់ប្រើប្រាស់នៅក្នុងបណ្តាញស៊ីញ៉ាល់លេខ ៧ (Signaling System No.7) សម្រាប់ការតភ្ជាប់បណ្តាញរវាងបមាណីស៊ីញ៉ាល់លេខ ៧ នៅក្នុងប្រទេស និងអន្តរជាតិ។

ការបែងចែកលេខកូដចំណុចស៊ីញ៉ាល់ជាតិត្រូវកំណត់ស្របតាមអនុសាសន៍ ITU-T Q.708 ដែលមានចំនួន ១៤ ប៊ីត ប៉ៃណារី កូដ (14-bits binary code) និងមានទម្រង់ដូចខាងក្រោម៖

| ទម្រង់/ខ្នង់ | International Signalling Point Codes (ISPC) | | |
|---|---|---|---|
| | X | Y | X |
| លេខប៊ីត (Bit) | 3 bits 000-111 | 8 bits 00000000-11111111 | 3 bits 000-111 |
| លេខនព្វន្ត (Decimal) | លេខពី 0 ដល់ 7 | លេខពី 0 ដល់ 255 | លេខពី 0 ដល់ 7 |